**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

គណៈកម្មការចំពោះកិច្ចវ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)
លេខ..០៩៧/២១....គ.វ.ក-១៩

ថ្ងៃសៅរ៍ ៦កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១

# សេចក្តីណែនាំ

## របស់ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)

## ស្តីពី

## ការចាក់វ៉ាក់សាំងដូសទី២ ជូនដល់បុគ្គលដែលកំពុងអនុវត្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

ដោយមានការយល់ព្រមដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាយប់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ និងដើម្បីចូលរួមចំណែកអនុវត្តវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឲ្យមានប្រសិទ្ធភាពខ្ពស់ គ.វ.ក-១៩ សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា បុគ្គលដែលកំពុងស្ថិតនៅក្នុងវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ហើយដល់ថ្ងៃដែលត្រូវចាក់វ៉ាក់សាំងដូសលើកទី២ មិនអនុញ្ញាតឱ្យបុគ្គលនោះធ្វើដំណើរទៅកាន់ទីកន្លែងចាក់វ៉ាក់សាំងដែលខ្លួនបានចាក់ដូសលើកទី១ ដោយសូមអញ្ជើញធ្វើទំនាក់ទំនងជាមួយមន្ទីរសុខាភិបាលរាជធានី-ខេត្ត ដែលបុគ្គលនោះកំពុងតែស្នាក់នៅ ដើម្បីទទួលបានការចាក់វ៉ាក់សាំងដូសលើកទី២ ដោយមិនឱ្យមានការហួសថ្ងៃកំណត់សម្រាប់ចាក់ដូសលើកទី២នោះឡើយ (នៅចន្លោះថ្ងៃទី១៤ ទៅថ្ងៃទី២៨ បន្ទាប់ពីថ្ងៃចាក់ដូសលើកទី១) ដើម្បីរក្សាគុណភាពវ៉ាក់សាំងក្នុងការបង្កើតបាននូវអង់ទីគ័រនៅក្នុងខ្លួនអ្នកដែលបានចាក់ដូសលើកទី១រួចហើយ។ ដោយឡែកថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១នេះ មានកកស្ទះការធ្វើដំណើររបស់បងប្អូន ចូលមករាជធានីភ្នំពេញ សូមទីតាំងចាក់វ៉ាក់សាំងទាំងអស់នៅទីក្រុងភ្នំពេញ ផ្អាកការចាក់វ៉ាក់សាំងចំនួន ៣ថ្ងៃសិន ដោយគិតចាប់ពីថ្ងៃទី១៧ ដល់ទី១៩ ខែមេសា ឆ្នាំ២០២១ នេះ។ ប្រសិនបើមានបុគ្គលដែលបានទៅដល់ទីតាំងចាក់វ៉ាក់សាំងរួចហើយនោះ សូមចាក់ជូនពួកគាត់ តែនៅពេលអស់មនុស្សដែលនៅរង់ចាំនៅទីតាំងចាក់វ៉ាក់សាំងសម្រាប់ហើយនោះ សូមផ្អាកការចាក់វ៉ាក់សាំងកូវីដ-១៩ នៅរាជធានីភ្នំពេញ ហើយនឹងដំណើរការចាក់ជាប្រក្រតីឡើងវិញចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១។

ក្នុងន័យនេះ គ.វ.ក-១៩ សូមធ្វើការណែនាំអំពីការចាក់វ៉ាក់សាំងដូសទី២ សម្រាប់អាជ្ញាធរខេត្ត និងសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ មន្ទីរសុខាភិបាលរាជធានី-ខេត្ត ព្រមទាំងបុគ្គលដែលកំពុងអនុវត្តវិធានការបិទខ្ទប់របស់រាជរដ្ឋាភិបាលនេះ ហើយដែលបុគ្គលមួយចំនួនដល់ថ្ងៃត្រូវចាក់ដូសលើកទី២ តែកំពុងតែស្នាក់នៅតាមរាជធានី-ខេត្ត ហើយមិនអាចធ្វើដំណើរមកចាក់នៅទីតាំងដែលខ្លួនបានចាក់លើកទី១បាន មានដូចតទៅ៖

- គ.វ.ក-១៩ នឹងផ្តល់ជូនវ៉ាក់សាំងស៊ីណូវ៉ាក់ចំនួន ៥.០០០ដូសចេញពីស្តុកបម្រុង ដើម្បីបន្ថែមជូនទៅរាជធានី-ខេត្ត ក្នុងចំនួន ២០០ដូសសម្រាប់មួយខេត្ត ដើម្បីចាក់ជូនដល់បុគ្គលដែលដល់ពេលវេលាត្រូវចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ ហើយ តែកំពុងជាប់ក្នុងស្ថានភាពបិទខ្ទប់នៅតាមរាជធានី-ខេត្តនានា ឧទាហរណ៍៖ បុគ្គលដែលចាក់វ៉ាក់សាំងស៊ី



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ណូវ៉ាក់លើកទី១នៅទីតាំងក្នុងរាជធានីភ្នំពេញ តែបច្ចុប្បន្នកំពុងតែជាប់បម្រាមធ្វើដំណើរនៅខេត្តណាមួយ ហើយត្រូវដល់ពេលទៅទទួលវ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ គឺបុគ្គលនោះ អាចទៅចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២បាន នៅតាមទីតាំងចាក់វ៉ាក់សាំងកំណត់ដោយមន្ទីរសុខាភិបាលខេត្តនោះ នៅក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់នេះ ដោយមិនចាំបាច់ធ្វើដំណើរវិលត្រឡប់មកកាន់រាជធានីភ្នំពេញវិញ ដើម្បីចាក់ដូសទី២នោះទេ។ អនុគណៈកម្មការគ្រប់គ្រងវ៉ាក់សាំងនៃ គ.វ.ក-១៩ នឹងដឹកជញ្ជូនវ៉ាក់សាំងនូវដូសដូចបានជម្រាបជូនខាងលើ ជូនដល់ខេត្តនិមួយៗ ចាប់ពីថ្ងៃអាទិត្យទី១៨ ខែមេសា ឆ្នាំ២០២១។

- អាជ្ញាធរមូលដ្ឋាន ឬសមត្ថកិច្ចនៅតាមមូលដ្ឋាន មិនត្រូវអនុញ្ញាត្តិឲ្យបុគ្គលធ្វើដំណើរឆ្លងខេត្ត-ក្រុង នៅក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់នេះ ក្នុងគោលបំណងទៅទទួលវ៉ាក់សាំងដូសទី២នោះឡើយ។ ដោយឡែក សម្រាប់បុគ្គលដែលកំពុងតែរស់នៅ ឬស្នាក់នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល សូមអាជ្ញាធររាជធានីភ្នំពេញ និងខេត្តកណ្តាល កំណត់ទីតាំងចាក់វ៉ាក់សាំងដែលនៅជិតពួកគាត់ ហើយសូមឱ្យអាជ្ញាធរមានសមត្ថកិច្ចគ្រប់ទីកន្លែង សម្រួលអនុញ្ញាតឱ្យបុគ្គលដែលមានតម្រូវការចាក់វ៉ាក់សាំងលើកទី២ (ប្រើប្រាស់កាតចាក់វ៉ាក់សាំងសម្រាប់អ្នកត្រូវចាក់ដូសលើកទី២ ជាមួយនិងអត្តសញ្ញាណបណ្ណសម្គាល់ខ្លួន និងតាមការសម្របសម្រួលរបស់ក្រសួង ស្ថាប័ន សម្រាប់បុគ្គលិក-មន្ត្រីរាជការស៊ីវិល បុគ្គលិកជាប់កិច្ចសន្យា ក្រុមគ្រួសារបុគ្គលិក-មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា (កំពុងតែធ្វើសម្រង់បញ្ជីឈ្មោះ) ដែលសាមីក្រសួង-ស្ថាប័នជាអ្នកគ្រប់គ្រងអ្នកចាក់វ៉ាក់សាំងនៅតាមក្រសួង-ស្ថាប័នរបស់ខ្លួន និងតាមការសម្របសម្រួលរបស់អាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ខណ្ឌ ខេត្ត ក្រុង រាជធានី ដែលមានទីតាំងចាក់វ៉ាក់សាំង ជូនដល់ប្រជាជនទូទៅដែលរស់នៅ ឬស្នាក់នៅតាមមូលដ្ឋានរបស់ខ្លួន សម្រាប់បុគ្គលដែលត្រូវចាក់ដូសលើកទី២ក្នុងពេលអនុវត្តវិធានការបិទខ្ទប់នេះ និងសម្រាប់អ្នកដែលត្រូវទៅចាក់ដូសលើកទី១ នាពេលខាងមុខនេះ បានធ្វើដំណើរទៅកាន់ទីតាំងដែលពួកគាត់ត្រូវចាក់វ៉ាក់សាំងទាំងលើកទី២ ឬលើកទី១ នៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដើម្បីពួកគាត់អាចបានទៅចាក់វ៉ាក់សាំងតាមពេលវេលាកំណត់នៅតាមទីតាំងដែលបានកំណត់ជូនពួកគាត់ ដោយមិនមានការខកខានឡើយ។ នាពេលឆាប់ៗខាងមុខនេះ នឹងមានការចាប់ផ្តើមចាក់ដូសលើកទី១នូវវ៉ាក់សាំងដែលទទួលបានជាបន្តបន្ទាប់ ដោយមានការសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** រួចហើយ គឺត្រូវសម្រុកចាក់ជូនដល់ក្រុមគោលដៅមួយចំនួនទៀតនៅរាជធានីភ្នំពេញឱ្យបានគ្រប់គ្នា ដូចជាក្រុមគ្រួសារបុគ្គលិក-មន្ត្រីរាជការស៊ីវិល និងបុគ្គលិកជាប់កិច្ចសន្យានៅរាជធានីភ្នំពេញជាដើម (គវ.ក-១៩ នឹងមានការជូនព័ត៌មានដោយឡែកអំពីការចាក់ដូសទី១ សម្រាប់នៅរាជធានីភ្នំពេញ)។
- ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវចំនួនបុគ្គលដែលជាប់នៅក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ដោយតម្រូវការអនុវត្តវិធានការបិទខ្ទប់ តែដល់ថ្ងៃត្រូវចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ ត្រូវចាត់ចែងឱ្យមានការជួយសម្របសម្រួលដល់ពួកគាត់ឲ្យបានចាក់វ៉ាក់សាំងដូសទី២ទៅតាមពេលវេលានៃការចាក់លើកទី២នេះ ដោយមិនឱ្យហួសពេលកំណត់ចាក់លើកទី២ នៅតាមមូលដ្ឋានសុខាភិបាលដែលនៅជិតពួកគាត់។ ក្នុងករណីមានការខ្វះខាតវ៉ាក់សាំងសម្រាប់ចាក់ជូនបុគ្គលដែលជាប់ក្នុងការអនុវត្តវិធានការបិទខ្ទប់លើសពីចំនួន ២០០ដូសដែលនឹងផ្តល់ជូនបន្ថែមនេះ សូមផ្តល់ដំណឹងមក គ.វ.ក-១៩ ឲ្យបានឆាប់បំផុត ដើម្បីធ្វើការផ្គត់ផ្គង់វ៉ាក់សាំងជូនបានទាន់ពេលវេលា។ លើសពីនេះទៀត មន្ទីរសុខាភិបាលរាជធានី-ខេត្ត ដែលមានវ៉ាក់សាំងនៅសល់ពីការចាក់ជូនប្រជាពលរដ្ឋនូវដូសទី២ហើយនោះ ត្រូវគ្រប់គ្រងវ៉ាក់សាំងដែលនៅសល់ឲ្យបានហ្មត់ចត់ ដោយមិនត្រូវយកទៅចាក់ខុសគោលដៅបានកំណត់ និងសូមរាយការណ៍ជូនមកគ.វ.ក-១៩ ដើម្បីធ្វើការពិនិត្យបែងចែកជូនដល់ទីតាំងដែលមានការខ្វះខាត។
- បុគ្គលដែលកំពុងជាប់ក្នុងបម្រាមធ្វើដំណើរ ហើយដល់ពេលវេលាត្រូវចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសទី២ (ចន្លោះពីថ្ងៃទី១៤ ដល់ថ្ងៃទី២៨ បន្ទាប់ពីថ្ងៃចាក់ដូសទី១រួច) សូមអញ្ជើញទៅទទួលវ៉ាក់សាំងដូសទី២នៅរាជធានី-ខេត្ត

ដែលខ្លួនកំពុងស្នាក់នៅ។ សូមអញ្ជើញធ្វើទំនាក់ទំនងជាមួយអាជ្ញាធរខេត្ត ក្រុង សង្កាត់ ស្រុក ឃុំ ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត ឬទីតាំងដែលមានចាក់វ៉ាក់សាំង ដោយបង្ហាញកាតចាក់វ៉ាក់សាំង និងអត្តសញ្ញាណបណ្ណសម្គាល់ខ្លួន ដើម្បីទទួលបានការសម្របសម្រួលឱ្យទៅចាក់វ៉ាក់សាំងនៅតាមទីតាំងដែលកំណត់ដោយមន្ទីរសុខាភិបាលខេត្តនោះ។ មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវកំណត់ទីតាំងសម្រាប់ចាក់វ៉ាក់សាំងដូសទី២ ហើយណែនាំដល់ទីតាំងចាក់វ៉ាក់សាំងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីសម្រួលដល់ការងារចាក់វ៉ាក់សាំងដូសទី២ ឱ្យបានល្អជូនដល់បងប្អូនដែលមានតម្រូវការចាក់ដូសទី២ តែជាប់ក្នុងការអនុវត្តន៍វិធានការបិទខ្ទប់នេះ។ សូមបងប្អូនប្រជាពលរដ្ឋ មេត្តាអត់ធ្មត់ គោរពតាមវិធានការរបស់រាជរដ្ឋាភិបាល ចៀសវាងការធ្វើដំណើរក្នុងរយៈពេលនៃបម្រាមបិទខ្ទប់នេះ ដើម្បីចូលរួមកាត់ផ្តាច់ការចម្លងវីរុសកូវីដ-១៩ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត បានឆាប់រហ័ស និងបានជៀសផុតពីគ្រោះមរណៈនៃជំងឺកូវីដ-១៩។

- មន្ទីរសុខាភិបាលរាជធានី-ខេត្ត ចាំបាច់ត្រូវរាយការណ៍ជូន គ.វ.ក-១៩ នូវចំនួនអ្នកដែលបានចាក់លើកទី២ ខាងលើនេះ រួមជាមួយនឹងរបាយការណ៍ជាប្រចាំថ្ងៃ ក្រោយពីបិទបញ្ចប់ការចាក់វ៉ាក់សាំងនៃថ្ងៃនិមួយៗ។ អ្នកដែលមិនបានចាក់ដូសទី២ ដោយមានមូលហេតុ ឬប្រការណាមួយ ចាំបាច់ត្រូវតែជូនដំណឹងតាមលេខទូរស័ព្ទខាងក្រោមនេះ ដើម្បីទទួលបានការណែនាំនៃការចាក់វ៉ាក់សាំងដូសទី២ បានទាន់ពេលវេលា។
- ការចាក់វ៉ាក់សាំងស៊ីណូហ្វាម វគ្គមុនៗ គឺបានចាក់ដូសទី២ចប់រួចរាល់ហើយ នៅសល់តែរាជធានីភ្នំពេញ ដែលកំពុងតែចាក់ជូនក្រុមគោលដៅនូវដូសលើកទី១ ដូច្នេះហាក់ដូចជាមិនទាន់មានបញ្ហា ឬចំណោទលើបុគ្គលដែលត្រូវការចាក់លើកទី២នៅឡើយ។ ប្រសិនបើមាន សូមបងប្អូន ផ្តល់ព័ត៌មានជូនតាមលេខទូរស័ព្ទខាងក្រោមនេះ ដើម្បី គ.វ.ក-១៩ ធ្វើការដោះស្រាយជូនទៅតាមសភាពជាក់ស្តែង ដោយមិនត្រូវចល័តពីកន្លែងមួយទៅកន្លែងមួយ នៅក្នុងដំណាក់កាលបម្រាមបិទខ្ទប់នេះទេ។
- ដោយឡែក សម្រាប់វ៉ាក់សាំងកូវីសែល (ដែលទទួលបានអាជ្ញាប័ណ្ណផលិតដោយអាស្ត្រាហ្សេនីកា) ពេលវេលាដែលត្រូវចាក់លើកទី២នោះ ត្រូវនៅចន្លោះសប្តាហ៍ទី ៨ និងទី១២ ដោយគិតចាប់ពីថ្ងៃដែលបានចាក់ដូសលើកទី១ ដែលវ៉ាក់សាំងប្រភេទនេះ មានចាក់នៅតែរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ប៉ុណ្ណោះ ។ សូមកត់សម្គាល់ថា មិនមាននៅសល់វ៉ាក់សាំងប្រភេទនេះ សម្រាប់ការបញ្ជូនទៅចាក់ខុសទីតាំងដែលបានចាក់លើកទី១បាននោះឡើយ ហើយពេលវេលានៃការចាក់លើកទី២ ក៏មិនទាន់ដល់នៅឡើយដែរ។ ប្រសិនបើមានការប្រែប្រួល ឬមានហេតុការណ៍ណាមួយនោះ សូមបងប្អូនជូនដំណឹងទៅ គ.វ.ក-១៩ ដើម្បីដោះស្រាយជូនតាមសភាពជាក់ស្តែងនាពេលខាងមុខនេះ ដោយទំនាក់ទំនងទៅលេខ ០១២ ៧៧៧ ៧៦០ ឬ ០១២ ៩១៦ ០៩៩ ឬ ០១២ ៩៨៩ ០៨៥ ឬ ០៩២ ៩៩៩ ៣៩៧។

គ.វ.ក-១៩ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានលះបង់កម្លាំងកាយចិត្ត និងប្រាជ្ញា គិតគូរខ្ពស់បំផុតដល់សុខភាពប្រជាជនទូទៅ និងបានផ្តល់លទ្ធភាពជូនដល់ប្រជាពលរដ្ឋកម្ពុជា និងជនបរទេស បានទទួលវ៉ាក់សាំងកូវីដ-១៩ និងបានដាក់ចេញនូវវិធានការការពារការចម្លងវីរុសកូវីដ-១៩ នានា ដែល គ.វ.ក-១៩ សូមធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ឱ្យមានភាពហ្មឺងម៉ាត់ ជឿជាក់ និងចូលរួមអនុវត្តវិធានការរបស់ប្រមុខរាជរដ្ឋាភិបាលដែលបានដាក់ចេញជាបន្តបន្ទាប់នេះ ដែលជាការបង្ហាញនូវការទទួលខុសត្រូវរបស់បងប្អូន ក្នុងការរួមចំណែកទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ និងរក្សាសុខភាពឱ្យបានល្អផ្ទាល់ខ្លួន ព្រមទាំងបង្កើតបាននូវសុខសុវត្ថិភាពជូនប្រទេសជាតិ។ សូមបងប្អូនប្រជាពលរដ្ឋ បន្តអនុវត្តវិធានការ **៣ការពារ** (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាព បុគ្គលពីមួយម៉ែត្រកន្លះឡើង) និង**៣កុំ** (កុំទៅកន្លែងមានមនុស្សកុះករច្រើន កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំចាប់ដៃគ្នា កុំឱប គ្នា កុំកៀកស្មាគ្នា) ឲ្យបានខ្ជាប់ខ្ជួនជានិច្ច ព្រោះបើទោះបីជាបងប្អូនបានចាក់វ៉ាក់សាំងរួចហើយក៏ដោយ ក៏ការចម្លងវីរុសកូវីដ-១៩ នៅតែអាចកើតមានបាន ប្រសិនបើបុគ្គលមិនបានអនុ

វត្តវិបានការពារខាងលើនេះបានត្រឹមត្រូវទេនោះ និងសូមនៅផ្ទះរៀងៗខ្លួនកុំចេញក្រៅដើររហេតរហូត ក្រែងប៉ះពារនឹងការឆ្លងវីរុសកូវីដ-១៩ នាំឱ្យមានជំងឺដ៏កាចសាហាវនេះ ដែលអាចឈានទៅរកសេចក្តីស្លាប់បានគ្រប់ពេលវេលា។

គ.វ.ក-១៩ ក៏សូមសំដែងនូវអំណរគុណ និងការកោតសរសើរជូនដល់ក្រុមគ្រូពេទ្យ-មន្ត្រីសុខាភិបាល អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច និងផ្នែកពាក់ព័ន្ធទាំងអស់ ដែលបាន និងកំពុងតែបន្តយកចិត្តទុកដាក់ផ្តល់សេវាចាក់វ៉ាក់សាំងជូនដល់ប្រជាពលរដ្ឋដោយមិនគិតពីការហត់នឿយ និងមិនមានថ្ងៃឈប់សម្រាកឡើយ ទោះជាថ្ងៃបុណ្យ ឬថ្ងៃចូលឆ្នាំប្រពៃណីយ៍ជាតិខ្មែរក៏ដោយ។

គ.វ.ក-១៩ សូមគោរពជូនពរបងប្អូនប្រជាពលរដ្ឋទាំងអស់នូវសុខភាពល្អបរិបូណ៌ ចៀសផុតនូវការចម្លងវីរុសកូវីដ-១៩ និងចៀសផុតនូវគ្រោះមរណៈជំងឺកូវីដ-១៩ ទាំងអស់គ្នា ។

**រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)**

វេជ្ជ. ឱ្យ_វណ្ណឌីន



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩